25.01.24
F0230

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ ០១១ អ.ស.ហ.ប្រ.ក

# ប្រកាស
## ស្តីពី
## ការស្នើសុំប្រើប្រាស់ការិយបរិច្ឆេទគណនេយ្យពិសេស

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
### និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២២/០០៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម



#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
#168F, St. 598, Chrang Chamres 1, Russei Keo, Phnom Penh
Website: fsa.gov.kh, Telegram: t.me/fsacambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩០ ៧០០
Phone: (+855) 23 990 700
info@fsa.gov.kh

- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ០០៧ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់និយ័តករគណនេយ្យនិងសវនកម្ម
- បានឃើញប្រកាសលេខ ០០១ អ.ស.ហ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម
- យោងតាមការអនុម័តនៅក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ លើកទី១៦ អាណត្តិទី១ នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះកំណត់លក្ខខណ្ឌ បែបបទ និងនីតិវិធីសម្រាប់ការស្នើសុំប្រើប្រាស់ការិយបរិច្ឆេទគណនេយ្យពិសេសក្នុងការរៀបចំបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ២._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## លក្ខខណ្ឌសម្រាប់ការស្នើសុំប្រើប្រាស់ការិយបរិច្ឆេទគណនេយ្យពិសេស

**ប្រការ៣._**

សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញអាចស្នើសុំប្រើប្រាស់ការិយបរិច្ឆេទគណនេយ្យពិសេសបាន ប្រសិនបើសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញនោះមានសកម្មភាពដែលត្រូវបានចាត់ទុកថាមានលក្ខណៈពិសេស។

ការិយបរិច្ឆេទគណនេយ្យពិសេស សំដៅដល់ការិយបរិច្ឆេទគណនេយ្យផ្សេងពីការិយបរិច្ឆេទដែលកំណត់ក្នុងមាត្រា២១ នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

**ប្រការ៤._**

សកម្មភាពដែលត្រូវបានចាត់ទុកថាមានលក្ខណៈពិសេស ត្រូវបានកំណត់ដូចខាងក្រោម÷

១. ចំពោះសហគ្រាស÷

- ជាបុត្រសម្ព័ន្ធ ឬញាតិសម្ព័ន្ធ ឬសាខាសហគ្រាសបរទេស ឬការិយាល័យតំណាង ដែលមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របទៅនឹងការិយបរិច្ឆេទគណនេយ្យ របស់សហគ្រាសមេនៅក្រៅប្រទេស
- ធ្វើប្រតិបត្តិការក្នុងវិស័យកសិកម្មដែលពាក់ព័ន្ធនឹងការដាំដុះ និងការចិញ្ចឹមសត្វ ដែលមានភាពចាំបាច់ក្នុងការផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យ
- ធ្វើប្រតិបត្តិការក្នុងវិស័យអប់រំដែលមានភាពចាំបាច់ក្នុងការផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យឱ្យស្របតាមពេលវេលានៃបវេសនកាលឆ្នាំសិក្សា
- ធ្វើសកម្មភាពក្នុងវិស័យអាទិភាពផ្សេងទៀត អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២. ចំពោះអង្គភាពមិនស្វែងរកប្រាក់ចំណេញ÷

- មានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របទៅនឹងការិយបរិច្ឆេទគណនេយ្យរបស់ស្ថាប័នម្ចាស់ជំនួយនៅក្រៅប្រទេស
- ធ្វើប្រតិបត្តិការក្នុងវិស័យអប់រំ ដែលមានភាពចាំបាច់ក្នុងការផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យឱ្យស្របតាមពេលវេលានៃបវេសនកាលឆ្នាំសិក្សា
- ធ្វើសកម្មភាពក្នុងវិស័យអាទិភាពផ្សេងទៀត អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៥._**

បែបបទ និងនីតិវិធីនៃការស្នើសុំប្រើប្រាស់ការិយបរិច្ឆេទគណនេយ្យពិសេស ត្រូវកំណត់ដោយនិយ័តករគណនេយ្យ និងសវនកម្ម (**ន.គ.ស.**)។

## ជំពូកទី៣

## ទោសប្បញ្ញត្តិ

**ប្រការ៦._**

សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ ដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**ប្រការ៧._**

សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបាននិងកំពុងប្រើប្រាស់ការិយបរិច្ឆេទគណនេយ្យពិសេស ផ្សេងពីការកំណត់ក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងលិខិតបទដ្ឋានជាធរមាន ដែលពុំទាន់ទទួលបានការ

អនុញ្ញាតពី **ន.គ.ស.** ត្រូវដាក់ពាក្យស្នើសុំមក **ន.គ.ស.** ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ)ខែ បន្ទាប់ពីថ្ងៃប្រកាសនេះចូលជាធរមាន។

ចំពោះសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលត្រូវបានបង្កើតឡើងក្រោយប្រកាសនេះចូលជាធរមាន ហើយមានបំណងស្នើសុំប្រើប្រាស់ការិយបរិច្ឆេទគណនេយ្យពិសេស ត្រូវដាក់ពាក្យស្នើសុំមក **ន.គ.ស.** យ៉ាងយូរ ១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬក្រសួងមហាផ្ទៃ ឬក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវបានបញ្ចប់រួចរាល់។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ៨._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩._**

អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងប្រធានអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងគ្រប់បុគ្គលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ.

  "ដើម្បីជូនជ្រាប"
- ដូចប្រការ៩

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ